ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ការិយាល័យទំនាក់ទំនងពាណិជ្ជកម្មកម្ពុជា

ប្រចាំនៅទីក្រុងណាននីង

លេខ0078 កពណក.ណន

## សូមគោរពជូន

## ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**<u>កម្មវត្ថុ</u>: របាយការណ៍ ប្រចាំខែ មករា ឆ្នាំ ២០១២**

សេចក្តីដូចបានជំរាបក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយស គោរពជូន **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ប្រចាំខែ មករា ឆ្នាំ២០១២ ដ៏ខ្ពង់ខ្ពស់ដូចតទៅ:

### I. ការងារទំនាក់ទំនងផ្សេងៗ:

- ជួបក្រុមហ៊ុន Yuan Chen (Beijing) International Investment Group មានបំណងស្វែងយល់វិស័យវិនិយោគនៅកម្ពុជា។
- ជួបក្រុមហ៊ុន Guangxi Raiway Investment Group Co.,Ltd និងក្រុមហ៊ុន Guangxi Guanxin Industry and Commerce Co.,Ltd មានបំណងវិនិយោគទុនលើវិស័យរ៉ែត្បូងនៅកម្ពុជា។
- ជួបមន្ទីរពាណិជ្ជកម្មនៅណាននីង ដើម្បីស្វែងរកទូរលេខនាំចេញ-នាំចូលរវាងខេត្តក្វាងស៊ី និងកម្ពុជា។
- ជួបក្រុមហ៊ុន Hua Lian Industry Co.,Ltd មានបំណងវិនិយោគក្នុងការដាំដំឡូងនៅប៉ៃលិន។
- ជួបក្រុមហ៊ុន Mining and Timber Industry Co.,Ltd មានបំណងវិនិយោគលើវិស័យរ៉ែ និងព្រៃឈើនៅកម្ពុជា។
- ចូលរួមបុណ្យខួបលើកទី៦៤ នៃថ្ងៃឯករាជ្យរបស់ប្រទេសភូមា។
- ជួប China South City ដើម្បីពិភាក្សាលំអិតនៃការតាំងលក់ផលិតផលកម្ពុជានៅ China – ASEAN Plaza។

*Address: No 11, Zhujin Road, China-ASEAN Business District, Nanning City, Guangxi, China*

*Tel/Fax: +86-771-5389496*
*Email : clo_cambodia@yahoo.com*

- ទស្សនកិច្ចនៅរោងចក្រផលិតម្សៅដំឡូង" Guangxi State Farm Ming Yang Biochemical Group,Inc " ដើម្បីស្វែងយល់ការកែច្នៃ និងតំលៃនាំចូលដំឡូងឈើពីវៀតណាមនិងថៃ ។

-ជួបពិភាក្សាជាមួយក្រុមហ៊ុន Sheng Ding Investment Group មានបំណងស្វែងយល់ច្បាប់វិនិយោគនៅកម្ពុជា ។

## II. សភាពការណ៍សេដ្ឋកិច្ចនៅសាធារណរដ្ឋប្រជាមានិតចិន:

សេដ្ឋកិច្ចរបស់ចិនពឹងផ្អែកទៅលើការនាំចេញទៅទីផ្សារអន្តរជាតិមានទីផ្សារសហគមន៍អឺរ៉ុបនិងទីផ្សារស.រ.អា ប៉ុន្តែបច្ចុប្បន្នដោយវិបត្តិប្រាក់បំណុលនៅ សហគមន៍អឺរ៉ុប និងការធ្លាក់ចុះសេដ្ឋកិច្ច ស.រ.អា ដែលធ្វើឱ្យការនាំចេញរបស់ចិនមានកំណើនយឺតៗ ។ តាមការទោះទាយបានបញ្ជាក់ថា សេដ្ឋកិច្ចរបស់ចិននឹងធ្លាក់ចុះក្នុងរយះពេល២ឆ្នាំកន្លះ ។ជាក់ស្តែងនៅក្នុងត្រីមាសទី៤ឆ្នាំ២០១១ សេដ្ឋកិច្ចចិនកើនឡើងយឺតៗ បានតែ៨.៩% ទាបជាងត្រីមាសទី៤ និងត្រីមាសទី២ ឆ្នាំ២០០៩ កន្លងទៅនេះ ។ គេរំពឹងថានៅក្នុងត្រីមាសទី១ ឆ្នាំ២០១២ សេដ្ឋកិច្ចចិននឹងកើនបានតែ៨% តែប៉ុណ្ណោះ ។

កន្លងមកអង្គការពាណិជ្ជកម្មពិភពលោក(WTO)បានចុះបញ្ជី ហើយបានចាត់ទុកប្រទេសចិនជាប្រទេសដែលរកចំណូលផ្នែកពាណិជ្ជកម្មចាត់ចំណាត់ថ្នាក់ទី២ក្នុងពិភពលោក ។ បច្ចុប្បន្នអង្គការWTOចាត់ទុកចិនចាត់ ចំណាត់ថ្នាក់ទី១ ក្នុងការរកចំណូលពាណិជ្ជកម្ម ។ ជាក់ស្តែងនៅក្នុងឆ្នាំ២០១០ចិនរកចំណូលផ្នែកពាណិជ្ជកម្មបានកើនដល់ ២៩៧ កោដិដុល្លា ស.រ.អា កើនបាន៦ដង បើធៀបជាមួយឆ្នាំ២០០១កន្លងមក ។

សេចក្តីដូចបានជំរាបជូនខាងលើ សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ប្រចាំខែ មករា ឆ្នាំ២០១២ ដ៏ខ្ពង់ខ្ពស់ដោយអនុគ្រោះបំផុត ។

សូម **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ក្រុងណានីង, ថ្ងៃទី 31 ខែមករា ឆ្នាំ ២០១២

ទីប្រឹក្សាពាណិជ្ជកម្ម

**អ៊ុច គឹមយ៉ុន**

ចម្លងជូន:

-អគ្គកុងស៊ុលនៅណានីង

-ឯកសារកាលប្បវត្តិ

*Address: No 11, Zhujin Road, China-ASEAN Business District, Nanning City, Guangxi, China*

*Tel/Fax : +86-771-5389496*

*Email : clo_cambodia@yahoo.com*